# ការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត

VOTE 2016

*អ្នកមានសិទ្ធិក្នុងការឈប់សម្រាកពីការងារដើម្បីទៅ បោះឆ្នោតដោយគ្មានការកាត់ប្រាក់បៀវត្សរ៍ ការឈប់ សម្រាប់ផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។*

និយោជករបស់អ្នកត្រូវទូទាត់ប្រាក់ជូនអ្នកសម្រាប់ពេលវេលាដែលអ្នកត្រូវទៅបោះឆ្នោត ប្រសិនបើថ្ងៃ បោះឆ្នោតចំម៉ោងការងារធម្មតារបស់អ្នក។ និយោជក របស់អ្នកមិនអាចតម្រូវឱ្យអ្នកប្រើប្រាស់ថ្ងៃឈប់សម្រាកផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

ចំណាយពេលវេលាដែលអ្នកត្រូវការចាំបាច់ដើម្បីទៅបោះឆ្នោត និងទៅធ្វើការ។

និយោជករបស់អ្នកមិនអាចបដិសេធ ដាក់កំហិត ឬរំខានដល់សិទ្ធិនេះដោយផ្ទាល់ ឬដោយប្រយោល ឡើយ រួមទាំងការជ្រើសរើសពេលវេលារបស់អ្នកដើម្បីទៅបោះឆ្នោតផងដែរ។
និយោជករបស់អ្នកអាចសុំឱ្យអ្នកប្រាប់គាត់អំពីពេលវេលាដែលអ្នកត្រូវទៅ និងសុំឱ្យបុគ្គលិកជួយសម្រប សម្រួលអវត្តមានរបស់ខ្លួនដើម្បីកាត់បន្ថយការអាក់ខាននៅកន្លែងធ្វើការ។

អ្នកមានសិទ្ធិឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោតនៅក្នុងគ្រប់ការបោះឆ្នោតប្រចាំរដ្ឋ និងសហព័ន្ធ និង នៅក្នុងគ្រប់ការបោះឆ្នោតក្នុងមូលដ្ឋានដែលបានកំណត់ពេលជាទៀងទាត់។

### កាលបរិច្ឆេទឆ្នាំ 2016

**ការបោះឆ្នោតបឋម**
*ថ្ងៃអង្គារ៍ទី09 ខែសីហា*

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
*បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី23 ខែកញ្ញា រហូតដល់ថ្ងៃទី7 ខែវិច្ឆិកា*

**ចុះឈ្មោះបោះឆ្នោត**
*ចុះឈ្មោះជាមុននៅត្រឹមថ្ងៃទី18 ខែតុលា ដើម្បីសន្សំសំចៃពេលវេលានៅថ្ងៃបោះឆ្នោត។*

**ថ្ងៃបោះឆ្នោត**
*ថ្ងៃអង្គារ៍ទី8 ខែវិច្ឆិកា*

## *ការដាក់ពាក្យប្តឹង*

និយោជកដែលរំលោភទៅលើច្បាប់នេះគឺមានបទល្មើសមជ្ឈិម។ រាល់បណ្តឹងពីបុគ្គលិកគួរដាក់ប្តឹងទៅមេធាវី ប្រចាំក្រុង។

*តទៅទំព័រក្រោយ...*

*ការិយាល័យលេខាធិការរដ្ឋ Minnesota*
*mnvotes.org • 1-877-600-VOTE*

# ការឈប់សម្រាកពីការងារ ដើម្បីទៅបោះឆ្នោត

VOTE 2016

.... តពីទំព័រមុខ

## *បោះឆ្នោតមុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន*

អ្នកអាចបោះឆ្នោតមុនពេលកំណត់ប្រសិនបើអ្នកមិន ចង់ទៅ ឬមិនអាចបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ ដោយ ចាប់ផ្តើមពីថ្ងៃសុក្រទី23 ខែកញ្ញា អាចបោះឆ្នោត មុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាននៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់ អ្នក។ អ្នកក៏អាចដាក់ពាក្យស្នើសុំឱ្យបញ្ជូនសន្លឹកឆ្នោត សម្រាប់ពលរដ្ឋអវត្តមានតាមលិខិតផងដែរ។

ដើម្បីស្វែងរកការិយាល័យបោះឆ្នោតក្នុង មូលដ្ឋានរបស់អ្នក ឬដើម្បីស្នើសុំសន្លឹកឆ្នោត សម្រាប់ ពលរដ្ឋអវត្តមាន សូមចូលទៅកាន់វេបសាយត៍ mnvotes.org។

### *លិខិតសម្រាប់និយោជករបស់អ្នក*

*សូមចូលទៅកាន់វេបសាយត៍ mnvotes.org ដើម្បី ស្វែងរកលិខិតដែលអ្នកអាចផ្តល់ជូននិយោជករបស់អ្នក ដើម្បីពន្យល់អំពីសិទ្ធិរបស់អ្នកក្នុងការឈប់សម្រាក ដើម្បីទៅបោះឆ្នោត។*

*ការិយាល័យលេខាធិការរដ្ឋ Minnesota*
*mnvotes.org • 1-877-600-VOTE*

ខែមីនា ឆ្នាំ2016